# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014
និង
របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី** |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | Co. 1698/03E |
| ទីស្នាក់ការចុះបញ្ជី | ផ្ទះលេខ 285 មហាវិថីកងយុទ្ធពលខេមរភូមិន្ទ (ផ្លូវលេខ 271)<br>សង្កាត់ទំនប់ទឹក ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ភាគទុនិក | Agora Microfinance N.V<br>Rural Impulse Fund II<br>PROPARCO<br>Cambodia-Laos Development Fund ("CLDF")<br>AMK Staff Association ("AMK-SA") |

| | | |
|---|---|---|
| ក្រុមប្រឹក្សាភិបាល | លោក Tanmay Chetan | ប្រធាន |
| | លោក Patrick Peter Power | អភិបាល |
| | លោក Tip Janvibol | អភិបាល |
| | លោកស្រី Mckenzie Ann Rebecca | អភិបាល |
| | លោក Adrian John Graham | អភិបាល |
| | លោក គា បូរាណ | អភិបាល |
| | លោកស្រី Blandine Claudia Marie Pons | អភិបាល |
| | លោក Joshua Morris | អភិបាល<br>(តែងតាំងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| | លោក Hannah M. Siedek | អភិបាល<br>(តែងតាំងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| | លោក Howard William Dalzell | អភិបាល<br>(លាលែងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| | លោក Thomas James O'Higgins | អភិបាល<br>(លាលែងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| អ្នកគ្រប់គ្រងជាន់ខ្ពស់ | លោក គា បូរាណ | ប្រធាននាយកប្រតិបត្តិ |
| | លោក ម៉ម ជឿន | ប្រធាននាយកប្រតិបត្តិប្រតិបត្តិការ |
| | លោក ឈាង តាំង | ប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ |
| | លោក ហ៊ួត សុខា | ប្រធាននាយកប្រតិបត្តិអាជីវកម្ម |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2. | របាយការណ៍របស់សវនករឯករាជ្យ | 7 |
| 3. | តារាងតុល្យការ | 9 |
| 4. | របាយការណ៍លទ្ធផល | 10 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | 11 |
| 6. | របាយការណ៍លំហូរទឹកប្រាក់ | 12 |
| 7. | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 13 |

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ ធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ហិរញ្ញវត្ថុរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ** (ពីមុនជា **អង្គរ មីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី**) ហៅកាត់ថា ("ក្រុមហ៊ុន" ឬ "អេ អឹម ខេ") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ** គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ជូនប្រជាពលរដ្ឋក្រីក្រកម្ពុជា តាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងតាមរយៈបណ្តាសាខាជាច្រើនទៀតនៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 មានដូចខាងក្រោម៖

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| ប្រាក់ចំណេញមុនដកពន្ធ | 20,563,859 | 5,046,345 | 16,275,893 | 4,074,066 |
| ពន្ធលើប្រាក់ចំណេញ | (4,250,267) | (1,043,010) | (3,055,981) | (764,951) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 16,313,592 | 4,003,335 | 13,219,912 | 3,309,115 |

## ដើមទុន

នៅថ្ងៃទី 20 ខែ តុលា ឆ្នាំ 2013 ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានអនុម័តបន្ថែមដើមទុនចំនួន 9,839 ហ៊ុន ឲ្យ AMK–SA គិតជាទឹកប្រាក់ចំនួន 245,976 ពាន់រៀល (61,570 ដុល្លារអាមេរិក) ដោយមានបុព្វលាភចំនួន 22,520 ពាន់រៀល (5,638 ដុល្លារអាមេរិក)។ ការបង្កើន ដើមទុននេះត្រូវបានអនុម័តដោយ ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 7 ខែ មីនា ឆ្នាំ 2014 និងក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 20 ខែ វិច្ឆិកា ឆ្នាំ 2014 ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## ដើមទុន (ត)

នៅថ្ងៃទី 24 ខែ មីនា ឆ្នាំ 2014 Concern Worldwide (Dublin) និង Concern Worldwide (UK) បានចុះ កិច្ចព្រមព្រៀងទិញលក់ជាមួយ PROPARCO និង CLDF និង Agora Microfinance N.V ដើម្បីលក់ហ៊ុនទាំងអស់របស់ខ្លួនដែលមាន ។ ការលក់នេះ អាចធ្វើបានលុះត្រាមានការអនុម័តពីធនាគារជាតិនៃកម្ពុជា ។ យោងតាមកិច្ចព្រមព្រៀងទិញលក់ Concern Worldwide (Dublin) យល់ព្រមលក់ 210,000 ហ៊ុនឲ្យ PROPARCO 94,200 ហ៊ុន ឲ្យ CLDF និង 437,428 ហ៊ុនឲ្យ Agora Microfinance N.V ហើយ Concern Worldwide (UK) យល់ព្រមលក់ 100 ហ៊ុន ឲ្យ Agora Microfinance N.V ។ ការបង្កើនដើមទុននេះត្រូវបានអនុម័តដោយ ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 4 ខែ សីហា ឆ្នាំ 2014 និង ក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 20 ខែ វិច្ឆិកា ឆ្នាំ 2014 ។

យោងតាមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនាថ្ងៃទី 24 ខែ មីនា ឆ្នាំ 2015 ក្រុមប្រឹក្សាភិបាលបានអនុម័តបែងចែកភាគលាភទៅឲ្យភាគទុនិកចំនួន 1,631,312 លានរៀល (400,322 ដុល្លារអាមេរិក) ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និង ការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ ឥណទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើង យ៉ាងគ្រប់គ្រាន់សម្រាប់ឥណទានដែលជាប់សង្ស័យ ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនាំឲ្យឥណទានអាក្រក់ដែលបានជំរះចេញពីបញ្ជី ឬចំនួនសំវិធានធនជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ក្រៅពីបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

ក្រុមប្រឹក្សាភិបាល មានមតិថាពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខ នៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាល មានមតិថាលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែល មានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាព ក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន:

| | |
|---|---|
| • លោក Tanmay Chetan | ប្រធាន |
| • លោក Patrick Peter Power | អភិបាល |
| • លោក Tip Janvibol | អភិបាល |
| • លោកស្រី Mckenzie Ann Rebecca | អភិបាល |
| • លោក Adrian John Graham | អភិបាល |
| • លោក គា បូរាណ | អភិបាល |
| • លោកស្រី Blandine Claudia Marie Pons | អភិបាល |
| • លោក Joshua Morris | អភិបាល (តែងតាំងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| • លោក Hannah M. Siedek | អភិបាល (តែងតាំងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| • លោក Howard William Dalzell | អភិបាល (លាលែងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |
| • លោក Thomas James O'Higgins | អភិបាល (លាលែងថ្ងៃទី 12 ខែ សីហា ឆ្នាំ 2014) |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ មានចំណែកភាគហ៊ុនដោយផ្ទាល់នៅក្នុងក្រុមហ៊ុនទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 និង លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ខ) អនុវត្តទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត ដែលអាចរំពឹងទុកបាន និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ** ដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី 9 ដល់ 59 ថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុនា ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល:*

ព្រះរាជាណាចក្រកម្ពុជា
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី
AMK Microfinance Institution Plc.
KINGDOM OF CAMBODIA

លោក Tanmay Chetan
*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី: 31 MAR 2015

KPMG

**KPMG Cambodia Ltd**
4th floor, Delano Center
No. 144, Street 169
Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia

Telephone +855 (23) 216 899
Fax +855 (23) 217 279
Internet www.kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិក
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី** ហៅកាត់ថា ("ក្រុមហ៊ុន" ឬ "អេ អឹម ខេ") ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 និងរបាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានសេចក្តីសង្ខេប លើគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 9 ដល់ទី 59 ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺការបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយផ្អែកលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ស្តង់ដារទាំងនោះ តម្រូវឲ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការនៃក្រមសីលធម៌ និងគ្រោង និងធ្វើសវនកម្មដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុ ពុំមានការបង្ហាញខុសជាសារវន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តនូវបណ្តានីតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងចំនួនទឹកប្រាក់ និងការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធីទាំងនេះ គឺផ្អែកលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណលើហានិភ័យដែលមានផលប៉ះពាល់ដល់ការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ បណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាលើការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីធ្វើសវនកម្មឲ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។ ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើងដោយអ្នកគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ។

KPMG Cambodia Ltd., a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity. All rights reserved.

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិសវនកម្ម

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

តំណាង **ក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

KPMG CAMBODIA LTD.

**ទៃ ហ៊ុយ**

*Audit Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 31 ខែ មីនា ឆ្នាំ 2015

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## តារាងតុល្យការ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | | 2014 | | 2013 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 25,603,288 | 6,283,015 | 13,051,323 | 3,266,914 |
| ប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | 6 | 25,339,156 | 6,218,198 | 14,788,065 | 3,701,643 |
| ប្រាក់បញ្ញើ និងប្រាក់ តម្កល់នៅធនាគារនានា | 7 | 21,794,178 | 5,348,265 | 44,592,049 | 11,161,965 |
| ឥណទានផ្តល់ដល់អតិថិជន | 8 | 388,323,570 | 95,294,128 | 313,393,956 | 78,446,547 |
| ទ្រព្យសកម្មផ្សេងៗ | 9 | 10,247,324 | 2,514,681 | 8,334,111 | 2,086,135 |
| ទ្រព្យ និងបរិក្ខារ | 10 | 11,188,578 | 2,745,663 | 8,143,319 | 2,038,378 |
| ទ្រព្យសកម្មអរូបិយ | 11 | 1,506,660 | 369,733 | 2,119,665 | 530,579 |
| ពន្ធពន្យារជាទ្រព្យសកម្មសុទ្ធ | 12 | 1,821,796 | 447,067 | 1,492,582 | 373,613 |
| **សរុបទ្រព្យសកម្ម** | | 485,824,550 | 119,220,750 | 405,915,070 | 101,605,774 |
| **បំណុល និងមូលធន** | | | | | |
| បំណុល | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 13 | 160,108,894 | 39,290,526 | 74,755,898 | 18,712,365 |
| សំវិធានធនសម្រាប់ពន្ធ លើប្រាក់ចំណេញ | 12 | 3,377,220 | 828,766 | 2,671,872 | 668,804 |
| បំណុលផ្សេងៗ | 14 | 17,989,074 | 4,414,498 | 12,453,341 | 3,117,231 |
| ប្រាក់កម្ចី | 15 | 199,153,791 | 48,872,096 | 228,745,576 | 57,257,966 |
| សំវិធានធនលើមូលនិធិ សោធនិវត្តន៍ | 16 | 7,296,514 | 1,790,556 | 5,702,918 | 1,427,514 |
| សរុបបំណុល | | 387,925,493 | 95,196,442 | 324,329,605 | 81,183,880 |
| មូលធន | | | | | |
| ដើមទុន | 17 | 35,127,300 | 8,620,196 | 34,881,325 | 8,731,245 |
| បុព្វលាភភាគហ៊ុន | 17 | 149,505 | 36,688 | 126,984 | 31,786 |
| ដើមទុនបង់មុន | 17 | - | - | 268,496 | 67,208 |
| ទុនបម្រុង | 18 | 11,228,229 | 2,755,394 | 8,551,904 | 2,140,652 |
| ប្រាក់ចំណេញរក្សាទុក | | 51,394,023 | 12,612,030 | 37,756,756 | 9,451,003 |
| សរុបមូលធន | | 97,899,057 | 24,024,308 | 81,585,465 | 20,421,894 |
| **សរុបបំណុល និងមូលធន** | | 485,824,550 | 119,220,750 | 405,915,070 | 101,605,774 |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## របាយការណ៍លទ្ធផល
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | | 2014 | | 2013 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| ចំណូលពីការប្រាក់ | 19 | 119,247,352 | 29,263,154 | 97,777,460 | 24,474,959 |
| ចំណាយការប្រាក់ | 20 | (30,133,655) | (7,394,762) | (25,980,544) | (6,503,265) |
| **ចំណូលពីការប្រាក់សុទ្ធ** | | 89,113,697 | 21,868,392 | 71,796,916 | 17,971,694 |
| កម្រៃសេវាកម្ម និងកម្រៃជើងសា | 21 | (9,032,614) | (2,216,592) | (7,110,828) | (1,779,932) |
| ចំណូលផ្សេងៗ | 22 | 4,299,587 | 1,055,113 | 3,082,553 | 771,603 |
| ចំណាយប្រតិបត្តិការផ្សេងៗ | 23 | (62,284,055) | (15,284,431) | (49,491,329) | (12,388,318) |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | 8 | (2,190,357) | (537,511) | (2,001,419) | (500,981) |
| **ចំណូលពីប្រតិបត្តិការ** | | 19,906,258 | 4,884,971 | 16,275,893 | 4,074,066 |
| ប្រាក់ជំនួយ | 24 | 657,601 | 161,374 | - | - |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 20,563,859 | 5,046,345 | 16,275,893 | 4,074,066 |
| ពន្ធលើប្រាក់ចំណេញ | 12 | (4,250,267) | (1,043,010) | (3,055,981) | (764,951) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 16,313,592 | 4,003,335 | 13,219,912 | 3,309,115 |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ តីអិលស៊ី

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | ដើមទុន | បុព្វលាភភាគហ៊ុន | ដើមទុនបង់មុន | ទុនបម្រុង | ប្រាក់ចំណេញរក្សាទុក | សរុប | |
|---|---|---|---|---|---|---|---|
| | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2013 | 34,579,200 | 95,506 | 333,603 | 5,928,121 | 27,160,627 | 68,097,057 | 17,045,571 |
| ការបន្ថែមដើមទុន | 302,125 | 31,478 | (303,603) | - | - | - | - |
| ដើមទុនបង់មុន | - | - | 268,496 | - | - | 268,496 | 67,208 |
| ផ្ទេរទៅទុនបម្រុង | - | - | - | 2,623,783 | (2,623,783) | - | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 13,219,912 | 13,219,912 | 3,309,115 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 | 34,881,325 | 126,984 | 268,496 | 8,551,904 | 37,756,756 | 81,585,465 | 20,421,894 |
| (សមមូលដុល្លារអាមេរិក - កំណត់សម្គាល់ 4) | 8,731,245 | 31,786 | 67,208 | 2,140,652 | 9,451,003 | 20,421,894 | |
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2013 | 34,881,325 | 126,984 | 268,496 | 8,551,904 | 37,756,756 | 81,585,465 | 20,421,894 |
| ការបន្ថែមដើមទុន | 245,975 | 22,521 | (268,496) | - | - | - | - |
| ផ្ទេរទៅទុនបម្រុង | - | - | - | 2,676,325 | (2,676,325) | - | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | 16,313,592 | 16,313,592 | 4,003,335 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 | 35,127,300 | 149,505 | - | 11,228,229 | 51,394,023 | 97,899,057 | 24,024,308 |
| (សមមូលដុល្លារអាមេរិក - កំណត់សម្គាល់ 4) | 8,620,196 | 36,688 | - | 2,755,394 | 12,612,030 | 24,024,308 | |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## របាយការណ៍លំហូរទឹកប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

| | កំណត់សម្គាល់ | 2014 ពាន់រៀល | 2014 ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | 2013 ពាន់រៀល | 2013 ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់ទទួលបានពី/(ប្រើក្នុង) សកម្មភាពប្រតិបត្តិការ | 25 | 59,742,922 | 14,660,840 | (2,614,487) | (654,442) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | | (5,776,149) | (1,417,460) | (4,904,774) | (1,227,728) |
| ការទិញទ្រព្យសកម្មអរូបិយ | | (233,248) | (57,239) | (703,058) | (175,984) |
| សាច់ប្រាក់ទទួលបានពីការលក់ ទ្រព្យ និងបរិក្ខារ | | 97,903 | 24,025 | 2,029 | 509 |
| សាច់ប្រាក់សុទ្ធប្រើក្នុង សកម្មភាពវិនិយោគ | | (5,911,494) | (1,450,674) | (5,605,803) | (1,403,203) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | 78,432,743 | 19,247,299 | 101,667,270 | 25,448,628 |
| ការទូទាត់សងប្រាក់កម្ចី | | (110,490,643) | (27,114,268) | (88,486,397) | (22,149,286) |
| ដើមទុនបង់មុន | | - | - | 268,496 | 67,208 |
| សាច់ប្រាក់សុទ្ធ(ប្រើក្នុង)/ទទួលបានពី សកម្មភាពហិរញ្ញប្បទាន | | (32,057,900) | (7,866,969) | 13,449,369 | 3,366,550 |
| **ការកើនឡើងនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 21,773,528 | 5,343,197 | 5,229,079 | 1,308,905 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | | 34,739,504 | 8,525,031 | 29,510,425 | 7,386,840 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 26 | 56,513,032 | 13,868,228 | 34,739,504 | 8,695,745 |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 1. អំពីក្រុមហ៊ុន

ក្រុមហ៊ុន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី (ត្រូវបានស្គាល់ពីមុនជា អង្គរមីក្រូហិរញ្ញវត្ថុ (កម្ពុជា) ខូ អិលធីឌី) ហៅកាត់ថា ("ក្រុមហ៊ុន" ឬ "អេ អឹម ខេ") គឺជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ មានអាជ្ញាប័ណ្ណ និង បានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការចុះបញ្ជី ពាណិជ្ជកម្មលេខ Co. 1698/03E នៅ ថ្ងៃទី 30 ខែ មេសា ឆ្នាំ 2003 ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមាន កម្រិត ។ នៅថ្ងៃទី 7 ខែ កក្កដា ឆ្នាំ 2014 ក្រុមហ៊ុនបានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនទៅជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី ។ សកម្មភាព ចម្បងរបស់ អេ អឹម ខេ គឺ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដល់ប្រជាពលរដ្ឋក្រីក្រកម្ពុជា តាមរយៈទីស្នាក់ការ កណ្តាលនៅរាជធានីភ្នំពេញ និងសាខាតាមបណ្តាខេត្ត ផ្សេងៗទៀតនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុន ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1999 ដោយ Concern Worldwide Cambodia ("CWC") ជាកម្មវិធីធនាគារ ពន្លឺថ្មី ហៅកាត់ថា ("TPT") ។ ទ្រព្យសកម្ម បំណុល និងប្រាក់ជំនួយសរុបទាំងអស់របស់ TPT ត្រូវបានផ្ទេរ កម្មសិទ្ធិទៅឲ្យក្រុមហ៊ុន នៅថ្ងៃទី 1 ខែ កក្កដា ឆ្នាំ 2003 ក្រោមទម្រង់ជាការបោះភាគហ៊ុន ។ អេ អឹម ខេ បានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅថ្ងៃផ្ទេរសិទ្ធិទ្រព្យសកម្មនោះ ។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណ ប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីសាធារណជន ដែលផ្តល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 29 ខែ មករា ឆ្នាំ 2010 ។

អេ អឹម ខេ មាន គោលការណ៍សំខាន់ៗ ដូចខាងក្រោម៖

- គ្រឹះស្ថាន អេ អឹម ខេ នឹងផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់ប្រជាជនក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាននិរន្តរភាពហិរញ្ញវត្ថុរឹងមាំនៅគ្រប់កម្រិត ។
- គ្រឹះស្ថាន អេ អឹម ខេ ប្តេជ្ញាបើកទូលាយ និងឲ្យមានតម្លាភាពនូវគ្រប់ផ្នែកទាំងអស់នៃការគ្រប់គ្រង និង ប្រតិបត្តិការ ។
- គ្រឹះស្ថាន អេ អឹម ខេ ប្តេជ្ញាធ្វើការអភិវឌ្ឍន៍ដំណើរការ/សេវាកម្ម និងប្រកាន់ខ្ជាប់នូវអត្តចរិត និងស្តង់ដារ ដើម្បីធានាឲ្យបាននូវការបម្រើសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់ដោយរួមទាំងការការពារអតិថិជន ។
- អេ អឹម ខេ គឺជាគ្រឹះស្ថានរៀនសូត្រដែលការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានដ៏សមស្រប នឹង រួមចំណែកដល់ការអភិវឌ្ឍន៍បុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងចូលរួមចំណែកក្នុងការកែលម្អ គោលការណ៍ និងប្រព័ន្ធ ។

ក្រុមហ៊ុនមានទីស្នាក់ការចុះបញ្ជីបច្ចុប្បន្ននៅអាគារលេខ 285 មហាវិថីកងយុទ្ធពលខេមរភូមិន្ទ (ផ្លូវលេខ 271) សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 ក្រុមហ៊ុនមានបុគ្គលិកចំនួន 1,740 នាក់ (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 មានចំនួន 1,444 នាក់) ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 2. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងកំណត់បង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី 31 ខែ មីនា ឆ្នាំ 2015 ។

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើមដំបូង ។

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណចំនួន 3 គឺ ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។ អ្នកគ្រប់គ្រងបានកំណត់ប្រាក់រៀលជារូបិយប័ណ្ណ មុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច ប្រភព ព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយ ប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ នាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់រៀល ក៏ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយ ប្រើអត្រានាកាលបរិច្ឆេទនោះ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបាន ទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែល មានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែលើការប៉ាន់ស្មាន គណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះ ត្រូវបាន កែប្រែ និងការិយបរិច្ឆេទអនាគតដែលប៉ះពាល់ដោយការកែប្រែនេះ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទ លើកលែងតែមានការបញ្ជាក់បន្ថែម ។

### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន សាច់ប្រាក់ និងសាច់ប្រាក់សមមូល ឥណទាន ផ្តល់ដល់អតិថិជន ប្រាក់បញ្ញើ គណនីត្រូវទទួលផ្សេងៗ ប្រាក់កម្ចី និងគណនីត្រូវទូទាត់ផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដូចខាងក្រោម ។

### (ខ) មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងបណ្តាសាខាតាមខេត្ត ក្រុងនានារបស់ខ្លួន ។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាទាំងអស់ត្រូវ បានលុបបំបាត់ចោល ។

### (គ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសមតុល្យសាច់ប្រាក់ និងធនាគារ និងប្រាក់បញ្ញើនៅ ធនាគារដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាង និងការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

ឥណទានវិបារូបន៍ ដែលត្រូវទូទាត់សងតាមតម្រូវការ ហើយជាផ្នែកមួយនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ត្រូវបានបញ្ចូលជាសមាសធាតុនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលក្នុងរបាយការណ៍លំហូរទឹកប្រាក់ ។

### (ឃ) ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជនដែលបានបង្ហាញនៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ ដោយដកចេញចំនួនទាំងឡាយណាដែលបានលុបចោល សំវិធានធនជាក់លាក់ និងសំវិធានធនទូទៅ ។

ឥណទានត្រូវបានលុបចោលជាស្វ័យប្រវត្ត នៅពេលដែលអតិថិជនទទួលមរណភាព និងនៅក្នុងករណីផ្សេងទៀតចំពោះឥណទានដែលមិនត្រូវបានទូទាត់សង ហើយត្រូវបានចាត់ទុកថាប្រមូលមិនបាន គឺត្រូវផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រង និងតាមការអនុម័តពីក្រុមប្រឹក្សាភិបាល ។ ឥណទានដែលបានលុបបំបាត់ចោលត្រូវបានកាត់ចេញពីឥណទានដែលនៅសល់ និងសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ។

### (ច) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុវត្តទៅតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនជាក់លាក់លើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានធ្វើឡើងលើឥណទានដែលបានចាត់ទុកថាមិនដំណើរការ ហើយត្រូវបានធ្វើឡើងដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| *ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ):* | | |
| ឥណទានក្រោមស្តង់ដារ | 30 ថ្ងៃ ឬលើស | 10% |
| ឥណទានជាប់សង្ស័យ | 60 ថ្ងៃ ឬលើស | 30% |
| ឥណទានបាត់បង់ | 90 ថ្ងៃ ឬលើស | 100% |
| *ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំ):* | | |
| ឥណទានក្រោមស្តង់ដារ | 30 ថ្ងៃ ឬលើស | 10% |
| ឥណទានជាប់សង្ស័យ | 180 ថ្ងៃ ឬលើស | 30% |
| ឥណទានបាត់បង់ | 360 ថ្ងៃ ឬលើស | 100% |

សំវិធានធនទូទៅបន្ថែមសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានកំណត់តាមអត្រា 1% នៃឥណទានស្តង់ដារទាំងអស់លើកលែងឥណទានផ្តល់ដល់បុគ្គលិក ។

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ច) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ (ត)

សំវិធានធននឹងត្រូវធ្វើការគណនាតាមភាគរយ នៃចំនួនសមតុល្យដែលនៅសល់នៅពេលដែលឥណទាននោះ ត្រូវបានចាត់ថ្នាក់ថាមិនដំណើរការ លើកលែងតែការប្រាក់បង្គរ ។ សំវិធានធនត្រូវបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន និងត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលរៀងរាល់ខែ នៅពេលដែលឥណទានត្រូវបានចាត់ថ្នាក់ក្រោមកម្រិតស្តង់ដារ ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានវាយតម្លៃដោយអ្នកគ្រប់គ្រងរៀងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយដែលត្រូវបានពិចារណាក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំឥណទាន បទពិសោធន៍នៃការខាតបង់កន្លងមក លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យា ។

ការប្រមូលបានមកវិញនូវឥណទាន ដែលបានលុបបំបាត់ចោលពីពេលមុន ត្រូវបានកាត់ចេញពីការខាតលើសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យនៅក្នុងរបាយការណ៍លទ្ធផល ។

#### (ឆ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃអាចប៉ាន់ស្មានពិត ។ ការប៉ាន់ស្មាន ត្រូវបានធ្វើឡើងសម្រាប់គណនីត្រូវទទួលដែលជាប់សង្ស័យ ដោយផ្អែកតាមការត្រួតពិនិត្យចំនួនដែលនៅសល់នាកាលបរិច្ឆេទរាយការណ៍ ។

#### (ជ) ទ្រព្យ និងបរិក្ខារ

(i) ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ នៅពេលដែលធាតុរបស់ទ្រព្យ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះ ត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នា) សមាសធាតុចម្បងៗរបស់ទ្រព្យ និងបរិក្ខារ ។

(ii) រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗ ដូចខាងក្រោម៖

| | |
|---|---|
| ការកែលំអអាគារ | 4 ឆ្នាំ |
| យានយន្ត | 8 ឆ្នាំ |
| ម៉ូតូ | 5 ឆ្នាំ |
| កុំព្យូទ័រ និងសម្ភារការិយាល័យ | 3 ទៅ 4 ឆ្នាំ |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ជ) ទ្រព្យ និងបរិក្ខារ (ត)

ទ្រព្យកំពុងបង្កើត មិនត្រូវបានគិត រំលស់ទេរហូតទាល់តែការសាងសង់បានបញ្ចប់ ហើយទ្រព្យ និងបរិក្ខារដែលពាក់ព័ន្ធ ត្រូវបានដាក់ប្រើសម្រាប់ធ្វើប្រតិបត្តិការអាជីវកម្ម ។

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមក ហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើ វាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀតត្រូវបាន ទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃឈប់ប្រើ ឬលក់ចេញ ។

(v) ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល ។

### (ឈ) ទ្រព្យសកម្មអរូបិយ

ទ្រព្យសកម្មអរូបិយ រួមមានកុំព្យូទ័រសូហ្វវែរ ហើយត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ។ ការទិញកុំព្យូទ័រសូហ្វវែរ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានទិញ និងនាំយកសូហ្វវែរនោះមកប្រើប្រាស់ ។ ទ្រព្យសកម្មអរូបិយ ត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរក្នុងរយៈពេល 5 ឆ្នាំ ។

### (ញ) ឱនភាពនៃតម្លៃ

*(i) ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះមានឱនភាពនៃតម្លៃ ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ ប្រសិនបើមានហេតុការណ៍មួយ ឬច្រើនជះឥទ្ធិពលជាអវិជ្ជមានលើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតដល់ទ្រព្យសកម្មនោះ ។ ករណីនេះ មិនត្រូវបានប្រើសម្រាប់ឥណទានផ្តល់ដល់អតិថិជននោះទេ ដោយវាត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកនៅក្នុងកំណត់សម្គាល់ 3 (ច) ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ញ) ឱនភាពនៃតម្លៃ (ត)

*(i) ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)*

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទោលសារវន្ត ត្រូវបានត្រួតពិនិត្យឱនភាពនៃតម្លៃតាមមូលដ្ឋានទោល ។ ទ្រព្យសកម្មនៅសល់ ត្រូវបានវាយតម្លៃជារួមក្នុងក្រុមទ្រព្យសកម្មដែលមានហានិភ័យឥណទានស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវដកចេញ ប្រសិនបើមានព្រឹត្តិការណ៍កើតឡើងបន្ទាប់ពីការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃតម្រូវឲ្យដកចេញ ។

*(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានវិញរបស់ទ្រព្យសកម្ម ត្រូវបានធ្វើឡើង ។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយដើម្បីលក់ចេញ ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមដែលអាចបង្កើតសាច់ប្រាក់បានតូចបំផុតពីការបន្តការប្រើប្រាស់ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា ("ឯកតាបង្កើតសាច់ប្រាក់") ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ដ) ប្រាក់បញ្ញើរបស់អតិថិជន

ប្រាក់បញ្ញើរបស់អតិថិជនត្រូវបានបង្ហាញតាមតម្លៃដើម ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឋ) ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានបង្ហាញតាមសមតុល្យប្រាក់ដើមដែលនៅសល់ ។ សោហ៊ុយផ្សេងៗ ដែលបានចំណាយដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានធ្វើមូលធនកម្ម និងធ្វើរំលស់ទៅតាមរយៈពេលនៃប្រាក់កម្ចីនោះ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ។

### (ឌ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាននាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។

### (ឍ) សំវិធានធនលើមូលនិធិសោធននិវត្តន៍

ក្រុមហ៊ុនផ្តល់អត្ថប្រយោជន៍ដល់និយោជិតរបស់ខ្លួន តាមគោលការណ៍មូលនិធិសោធននិវត្តន៍ ។ និយោជិតដែលបានបញ្ចប់រយៈពេលសាកល្បង មានសិទ្ធិចូលរួមក្នុងមូលនិធិសោធននិវត្តន៍នេះ ។ មូលនិធិនេះមានប្រភពមកពីកត្តាដូចខាងក្រោម៖

- និយោជិតចូលរួមចំណែកចំនួន 3% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់ពួកគេ ហើយក្រុមហ៊ុនចូលរួមចំណែកចំនួន 6% ។ ការរួមចំណែកនេះ ត្រូវបានកត់ត្រាជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ។
- ក្រុមហ៊ុនផ្តល់ការប្រាក់លើសមតុល្យបង្គរនៃមូលនិធិសោធននិវត្តន៍ ដែលត្រូវបានគណនាតាមអត្រា 7% ក្នុងមួយឆ្នាំ ។ ការប្រាក់នេះ ត្រូវបានកត់ត្រាជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ។

មូលនិធិសោធននិវត្តន៍ នឹងត្រូវទូទាត់ជូននិយោជិត (និយោជិតដែលបានចូលរួមចំណែកក្នុងមូលនិធិ) នៅពេលដែលពួកគេចូលនិវត្តន៍ លាឈប់ពីការងារ ឬត្រូវបញ្ឈប់ពីការងារ ។ ចំនួនដែលនិយោជិតបានរួមចំណែក ព្រមទាំងការប្រាក់ ត្រូវបានក្រុមហ៊ុនទូទាត់ជូនយ៉ាងពេញលេញ ។

និយោជិតទាំងឡាយណាដែលត្រូវបានបញ្ឈប់ពីការងារ ដោយសារការប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរទទួលបានមូលនិធិនេះត្រឹមចំណែកដែលនិយោជិតនោះបានបង់ និងការប្រាក់ប៉ុណ្ណោះដោយមិនគិតអតីតភាពការងាររបស់និយោជិតរូបនោះឡើយ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) ការទទួលស្គាល់ប្រាក់ចំណូល និងចំណាយ

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ ។ នៅពេលដែលឥណទានមួយត្រូវបានចាត់ថ្នាក់ជាឥណទានមិនដំណើរការ ការកត់ត្រាចំណូលពីការប្រាក់ត្រូវបានព្យួរទុក រហូតដល់ពេលដែលក្រុមហ៊ុនបានទទួលសាច់ប្រាក់ជាក់ស្តែង ។ ចំណូលពីការប្រាក់ត្រូវបានធ្វើការគណនាដោយប្រើវិធីសាស្ត្រសមតុល្យថយចុះលើសមតុល្យឥណទានដែលនៅសល់ប្រចាំខែ ។

កម្រៃសេវាកម្មឥណទាន ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលដែលទឹកប្រាក់ឥណទានត្រូវបានផ្តល់ដល់អតិថិជន ។ កម្រៃសេវាកម្មឥណទានត្រូវបានគណនាដោយប្រើប្រាស់ប្រាក់ដើម និងអត្រាកម្រៃសេវាកម្ម ។

ចំណាយត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ។

### (ត) ជំនួយ

ជំនួយដែលទទួលបានពីភាគីទីបី ដើម្បីជួយលើប្រតិបត្តិការទាំងឡាយរបស់ក្រុមហ៊ុន ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល ផ្អែកតាមមូលដ្ឋានជាប្រព័ន្ធ និងសមស្របដោយផ្គូផ្គងជាមួយនឹងចំណាយដែលត្រូវទូទាត់ ។

ជំនួយដែលទទួលបានពីភាគីទីបី សម្រាប់ការទិញទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណូលក្នុងរបាយការណ៍លទ្ធផល ផ្អែកតាមមូលដ្ឋានជាប្រព័ន្ធ និងសមស្របទៅតាមអាយុកាលនៃការប្រើប្រាស់របស់ទ្រព្យសម្បត្តិ ។ ជំនួយដែលមិនទាន់បានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផល ត្រូវបានបង្ហាញជាជំនួយពន្យារ ។

### (ថ) ភតិសន្យា

ទ្រព្យសកម្មដែលកាន់កាប់ដោយក្រុមហ៊ុនស្ថិតក្រោមភតិ ដែលក្រុមហ៊ុនទទួលយកហានិភ័យចម្បងៗ និងកម្មសិទ្ធិនៃទ្រព្យសកម្ម ត្រូវបានចាត់ជាភតិសន្យាហិរញ្ញវត្ថុ ។ ក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មភតិសន្យា ត្រូវបានវាស់វែងតាមចំនួនស្មើនឹងតម្លៃសមស្របនៃទ្រព្យសកម្ម (ឬ ប្រសិនបើទាបជាងនេះ ការទូទាត់អប្បបរមាលើភតិសន្យា) នៃតម្លៃរបស់ភតិ ។ ការទទួលស្គាល់បំណុលត្រូវបានរួមបញ្ចូលក្នុងរបាយការណ៍តុល្យការ ដូចនឹងបំណុលទ្រព្យសកម្មភតិសន្យា ។ ការទូទាត់ភតិត្រូវបានទូទាត់រវាងថ្លៃ និងការកាត់កងនៃបំណុលភតិសន្យា ដើម្បីទទួលបានអត្រាថេរនៃការប្រាក់លើសមតុល្យដែលនៅសល់ នៃបំណុល ។ ថ្លៃត្រូវបានកាត់ចេញក្នុងរបាយការណ៍លទ្ធផល ។ ទ្រព្យសកម្មដែលស្ថិតក្រោមភតិសន្យាត្រូវបានរួមបញ្ចូលក្នុងទ្រព្យ និងបរិក្ខារ ហើយការរំលស់ និងវាយតម្លៃសម្រាប់ធ្វើសំវិធានធនធ្វើឡើងដូចគ្នាទៅនឹងការកាន់កាប់ទ្រព្យសកម្ម ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ភតិសន្យា (ត)

ថ្លៃឈ្នួលដែលត្រូវទូទាត់លើភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្រ្តរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ការសន្យាភតិសន្យា មិនត្រូវបានទទួលស្គាល់ជាបំណុលទេរហូតដល់ពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចត្រូវទូទាត់ ។

### (ទ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលពន្ធលើប្រាក់ចំណេញទាក់ទងទៅនឹងធាតុណាដែលបានទទួលស្គាល់ជាផ្នែកមួយនៃមូលធន ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថា ត្រូវបង់លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើ អត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកំណត់តាមវិធីសាស្រ្តតារាងតុល្យការលើភាពលំអៀងបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។ ចំនួននៃពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈដែលអាចប្រើប្រាស់បាន ឬអាចកាត់កងបានដែលនឹងកើតឡើងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតារាងតុល្យការ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងនូវប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដែលអនុញ្ញាតឲ្យប្រើប្រាស់កាត់កងជាមួយពន្ធពន្យារនោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកាត់បន្ថយ ក្នុងករណីមិនអាចមាននូវការប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។

### (ធ) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលខ្លាំងលើភាគីមួយទៀតក្នុងការធ្វើសេចក្តីសម្រេចហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬក្រុមហ៊ុន និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយក៏រួមបញ្ចូលនូវសមាជិកគ្រួសារជិតស្និទ្ធជាមួយនឹងរូបវន្តបុគ្គលជាសម្ព័ន្ធញាតិផងដែរ ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ផ) សម្ព័ន្ធញាតិ (ត)

តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្ព័ន្ធញាតិរួមបញ្ចូលផងដែរនូវរូបវន្តបុគ្គលដែលមានភាគហ៊ុនយ៉ាងតិចចំនួន 10% នៃដើមទុនរបស់ក្រុមហ៊ុន ឬនៃសិទ្ធិបោះឆ្នោត ទោះជាកាន់កាប់ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឬរូបវន្តបុគ្គលណាដែលរួមចំណែកក្នុងផ្នែករដ្ឋបាល ការដឹកនាំ ការគ្រប់គ្រង ឬការរៀបចំ និងការអនុវត្តនូវការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន ។

## 4. ការប្តូររូបិយប័ណ្ណពីប្រាក់រៀលទៅជាប្រាក់ដុល្លារអាមេរិក

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀល ។ ការប្តូររូបិយប័ណ្ណពីប្រាក់រៀលទៅជាប្រាក់ដុល្លារអាមេរិក ត្រូវបានធ្វើឡើងសម្រាប់ជាការបង្ហាញប៉ុណ្ណោះ ដោយប្រើអត្រាប្តូរប្រាក់មធ្យមជាផ្លូវការប្រកាសដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014 ដែល 1 ដុល្លារអាមេរិក ស្មើនឹង 4,075 រៀល (2013: 1 ដុល្លារអាមេរិក ស្មើនឹង 3,995 រៀល) ។ តួលេខជាប្រាក់រៀលនេះ មិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ឬនឹងត្រូវប្តូរជាប្រាក់ដុល្លារអាមេរិក នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

## 5. សាច់ប្រាក់ក្នុងដៃ

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| ទីស្នាក់ការកណ្តាល | 824,090 | 202,230 | 34,573 | 8,654 |
| សាខាផ្សេងៗ | 24,779,198 | 6,080,785 | 13,016,750 | 3,258,260 |
| | 25,603,288 | 6,283,015 | 13,051,323 | 3,266,914 |

## 5. សាច់ប្រាក់ក្នុងដៃ (ត)

ចំនួនខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោមៈ

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| តាមរូបិយប័ណ្ណ: | | | | |
| ប្រាក់រៀល | 13,432,466 | 3,296,311 | 7,536,863 | 1,886,574 |
| ប្រាក់ដុល្លារអាមេរិក | 11,185,981 | 2,745,026 | 5,084,452 | 1,272,703 |
| ប្រាក់បាតថៃ | 984,841 | 241,678 | 430,008 | 107,637 |
| | 25,603,288 | 6,283,015 | 13,051,323 | 3,266,914 |

## 6. ប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| ប្រាក់បញ្ញើតាមច្បាប់: | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន | 3,512,730 | 862,020 | 3,488,133 | 873,125 |
| ប្រាក់បម្រុងកាតព្វកិច្ច | 11,813,620 | 2,899,048 | 5,679,500 | 1,421,652 |
| | 15,326,350 | 3,761,068 | 9,167,633 | 2,294,777 |
| គណនីចរន្តផ្សេងៗ | 10,012,806 | 2,457,130 | 5,620,432 | 1,406,866 |
| | 25,339,156 | 6,218,198 | 14,788,065 | 3,701,643 |

### ប្រាក់តម្កល់ធានាលើដើមទុន

ប្រាក់បញ្ញើតាមច្បាប់ត្រូវបានរក្សាទុកនៅ ធនាគារជាតិនៃកម្ពុជាដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-00-006 ប្រ.ក ស្តីពីអាជ្ញាប័ណ្ណនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំនួន 10% នៃដើមទុនចុះបញ្ជី ។ ប្រាក់តម្កល់នេះ នឹងត្រូវបង្វិលឲ្យក្រុមហ៊ុនវិញ នៅពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន ហើយមិនមាននៅសល់ប្រាក់បញ្ញើរបស់អតិថិជន ។

ប្រាក់តម្កល់ធានាលើដើមទុនរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ទទួលបានការប្រាក់តាមអត្រា 3.00% ក្នុងមួយឆ្នាំ ។

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 6. ប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា (ត)

ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា 8% នៃប្រាក់បញ្ញើរបស់អតិថិជន ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-07-163 ប្រ.ក ស្តីពីអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណៈជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ប្រាក់បញ្ញើនេះប្រែប្រួលតាមកម្រិតនៃប្រាក់បញ្ញើរបស់អតិថិជន ។

ប្រាក់បម្រុងកាតព្វកិច្ច ពុំទទួលបានការប្រាក់នោះទេ ។

## 7. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| គណនីចរន្ត | 1,338,170 | 328,385 | 1,551,615 | 388,389 |
| គណនីសន្សំ | 19,558,768 | 4,799,698 | 14,516,134 | 3,633,576 |
| គណនីមានកាលកំណត់ | 897,240 | 220,182 | 28,524,300 | 7,140,000 |
| | 21,794,178 | 5,348,265 | 44,592,049 | 11,161,965 |

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានធ្វើការវិភាគដូចខាងក្រោមៈ

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| (ក) តាមកាលកំណត់: | | | | |
| ក្នុងរយៈពេល 1 ខែ | 20,896,938 | 5,128,083 | 16,067,749 | 4,021,965 |
| លើសពី 3 ខែ | 897,240 | 220,182 | 28,524,300 | 7,140,000 |
| | 21,794,178 | 5,348,265 | 44,592,049 | 11,161,965 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 7. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា (ត)

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានធ្វើការវិភាគដូចខាងក្រោម (ត)៖

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| (ខ) តាមរូបិយប័ណ្ណ: | | | | |
| ប្រាក់ដុល្លារអាមេរិក | 6,302,113 | 1,546,531 | 32,124,387 | 8,041,148 |
| ប្រាក់រៀល | 14,058,180 | 3,449,860 | 10,308,789 | 2,580,423 |
| ប្រាក់បាតថៃ | 1,433,885 | 351,874 | 2,158,873 | 540,394 |
| | 21,794,178 | 5,348,265 | 44,592,049 | 11,161,965 |

(គ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ):

| | 2014 | 2013 |
|---|---|---|
| គណនីមានកាលកំណត់ | 1.00% - 5.00% | 1.00% - 5.00% |
| គណនីសន្សំ | 0.25% - 0.75% | 0.25% - 0.75% |

## 8. ឥណទានផ្តល់ដល់អតិថិជន

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| ឥណទានធនាគាភូមិ៖ | | | | |
| សងនៅចុងវគ្គ | 92,737,423 | 22,757,650 | 86,804,078 | 21,728,180 |
| សងរំលស់ដើមថេរ | 68,562,582 | 16,825,173 | 64,756,592 | 16,209,410 |
| សងបណ្តាក់ | 89,952,590 | 22,074,255 | 82,531,966 | 20,658,815 |
| ឥណទានឯកត្តជន៖ | | | | |
| សងបណ្តាក់ | 81,519,375 | 20,004,755 | 37,097,151 | 9,285,895 |
| សងនៅចុងវគ្គ | 27,981,405 | 6,866,602 | 26,589,948 | 6,655,807 |
| សងបណ្តាក់តាមរដូវកាល | 24,641,850 | 6,047,080 | 13,345,734 | 3,340,609 |
| ឥណទានផ្តល់ដល់បុគ្គលិក | 7,164,205 | 1,758,088 | 5,713,223 | 1,430,093 |
| | 392,559,430 | 96,333,603 | 316,838,692 | 79,308,809 |

## 8. ឥណទានផ្តល់ដល់អតិថិជន (ត)

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | | | | |
| ជាក់លាក់ | (381,907) | (93,720) | (333,494) | (83,478) |
| ទូទៅ | (3,853,953) | (945,755) | (3,111,242) | (778,784) |
| | (4,235,860) | (1,039,475) | (3,444,736) | (862,262) |
| | 388,323,570 | 95,294,128 | 313,393,956 | 78,446,547 |

បម្រែបម្រួលនៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចខាងក្រោម៖

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| នាថ្ងៃទី 1 ខែ មករា | 3,444,736 | 845,334 | 2,617,310 | 655,147 |
| សំវិធានធនបន្ថែមក្នុងការិយបរិច្ឆេទ | 2,190,357 | 537,511 | 2,001,419 | 500,981 |
| ការលុបចេញពីបញ្ជីក្នុងការិយបរិច្ឆេទ | (1,399,233) | (343,370) | (1,173,993) | (293,866) |
| នាថ្ងៃទី 31 ខែ ធ្នូ | 4,235,860 | 1,039,475 | 3,444,736 | 862,262 |

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| (ក) តាមកាលកំណត់: | | | | |
| តិចជាង 1 ខែ | 27,578,395 | 6,767,704 | 25,298,229 | 6,332,473 |
| ពី 1 ទៅ 3 ខែ | 96,374,429 | 23,650,167 | 89,867,488 | 22,494,991 |
| ពី 3 ខែ ទៅ 12 ខែ | 194,883,146 | 47,824,085 | 163,426,887 | 40,907,857 |
| លើសពី 1 ឆ្នាំ | 73,723,460 | 18,091,647 | 38,246,088 | 9,573,488 |
| | 392,559,430 | 96,333,603 | 316,838,692 | 79,308,809 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2014

## 8. ឥណទានផ្តល់ដល់អតិថិជន (ត)

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោមៈ (ត)

| | 2014 | | 2013 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ 4) |
| (ខ) តាមរូបិយប័ណ្ណ: | | | | |
| ប្រាក់រៀល | 306,560,958 | 75,229,683 | 267,818,619 | 67,038,453 |
| ប្រាក់ដុល្លារអាមេរិក | 61,655,088 | 15,130,083 | 31,705,803 | 7,936,371 |
| ប្រាក់បាតថៃ | 24,343,384 | 5,973,837 | 17,314,270 | 4,333,985 |
| | 392,559,430 | 96,333,603 | 316,838,692 | 79,308,809 |
| (គ) តាមផ្នែកសេដ្ឋកិច្ច: | | | | |
| កសិកម្ម | 219,000,713 | 53,742,506 | 171,266,901 | 42,870,313 |
| ពាណិជ្ជកម្ម និងជំនួញ | 74,253,792 | 18,221,789 | 60,825,843 | 15,225,493 |
| លក្ខណៈគ្រួសារ | 14,464,789 | 3,549,641 | 6,690,813 | 1,674,797 |
| សេវាកម្ម | 18,427,405 | 4,522,063 | 60,518,575 | 15,148,579 |
| សំណង់ | 63,158,805 | 15,499,093 | 9,151,474 | 2,290,732 |
| ការដឹកជញ្ជូន | 3,220,481 | 790,302 | 1,704,466 | 426,650 |
| ផ្សេងៗ | 33,445 | 8,209 | 6,680,620 | 1,672,245 |
